## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

~~~***~~~

សាលាដំបូងខេត្តកណ្តាល

សាលក្រមព្រហ្មទណ្ឌលេខ: ២៦៥(ធ)

ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**មេធាវី**

លោក [redacted] មេធាវីការពារក្តីឲ្យដើមបណ្តឹងរដ្ឋប្បវេណី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: ០៥៦ អក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] សុខឃីម ភេទស្រី អាយុ៥៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅ [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] អ៊ួយ (ស្លាប់) ម្តាយឈ្មោះ [redacted] ស៊ួយ (ស្លាប់) ប្តីឈ្មោះ [redacted] ហួល គ្មានកូន ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ពីបទ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិអូរកំបុត ឃុំព្រៃព្រួច ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងឈ្មោះ [redacted] បូរ៉ា ភេទប្រុស អាយុ៤៣ឆ្នាំ ជាជាតិខ្មែរ មុខរបរមេធាវី មានទីលំនៅបច្ចុប្បន្ន ភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

**ដំណើររឿងមានដូចតទៅ**

កាលពីដើមឆ្នាំ២០១៩ មានករណី រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិស្វាយ ឃុំព្រៃព្រួច ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលបង្កឡើងដោយជនដោយជនជាប់ចោទឈ្មោះ [redacted] សុខឃីម បានសុំឈ្មោះ [redacted] បូរ៉ា ធ្វើស្រែប្រវាស់ ដោយសន្យាថាពេលបានផលស្រូវ បែងចែកផលស្មើគ្នាទៅតាមរដូវ និងតាមចំនួនផលដែលទទួលបានជាក់ស្តែង ដោយឈ្មោះ [redacted] សុខឃីម ចេញកម្លាំងពលកម្ម ។ លុះក្រោយមកចុងឆ្នាំ២០១៩ ឈ្មោះ [redacted] សុខឃីម មិនបានបែងចែកផលស្រូវទៅឲ្យឈ្មោះ [redacted] បូរ៉ា នោះទេ ដោយបានគេចវេស ។ លុះដល់ថ្ងៃទី២០ ខែធ្នូ

Scanned with CamScanner
~~~

ឆ្នាំ២០១៩ ឈ្មោះ [redacted] បូរ៉ា បានទូរស័ព្ទទៅឈ្មោះ [redacted] សុខឃីម ដើម្បីទារចំណែកស្រូវ ស្រាប់តែឈ្មោះ [redacted] សុខឃីម មិនឲ្យផលស្រូវទៅឈ្មោះ [redacted] បូរ៉ា នោះទេ ដោយនិយាយថាខ្លួនធ្វើស្រែអត់ចំណេញទេ ។

## បានឃើញ

-ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះលេខផ្ទាល់លេខៈ ៤៩៧ ដក.ជវជ/២០ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-ដីកាចាត់តាំងចៅក្រមជំនុំជម្រះផ្ទាល់លេខៈ ១៤៣៩ ដកចត/២០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ការសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

## សំអាងហេតុ

១-កាលពីអំឡុងឆ្នាំ២០១៩ ស្ថិតនៅភូមិស្វាយ ឃុំព្រៃព្រួច ស្រុកអង្គស្នួល ខេត្តកណ្តាល ពិតជាកើតមាននូវអំពើ រំលោភលើទំនុកចិត្ត ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] សុខឃីម បានធ្វើសកម្មភាពលួងលោមយកដីរបស់ជនរងគ្រោះមកធ្វើស្រែ ដោយសន្យាថាពេលបានផលស្រូវ នឹងចែកស្រូវឲ្យជនរងគ្រោះមួយចំនួន ក្រោយពេលបានផលហើយជនជាប់ចោទបែជាមិនផលស្រូវនោះទៅឲ្យជនរងគ្រោះថែមទាំងគេចវេស។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខឃីម បានឆ្លើយថាៈ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ឈ្មោះ [redacted] បូរ៉ា បានមកទាក់ទងខ្លួនឲ្យខ្លួនធ្វើស្រែឲ្យ ពេលនោះខ្លួនក៏បានយល់ព្រមហើយក៏និយាយថា ឲ្យខ្លួនធ្វើមក ចាំខ្លួនឲ្យអង្ករមួយឯងហូប ។ លុះដល់ដើមឆ្នាំ២០២៩ ឈ្មោះ [redacted] បូរ៉ា ក៏បានឲ្យខ្លួនធ្វើស្រែជាធម្មតាដដែលហើយនៅពេលបានផលខែសីហា ដដែលនេះស្រែដែលខ្លួនធ្វើនោះ បានលិចទឹក និងដុះស្រូវ សារជាថ្មីតិចៗ តែនៅពេលនោះខ្លួន បានស្ទូងបន្ថែមចំនុចដែលនៅចន្លោះៗ ហើយខ្លួនទទួលផលនៅខែវិច្ឆិកា ឆ្នាំ ២០១៩ បានចំនួនស្រូវ ១៥០គីឡូក្រាម បន្ទាប់មកឈ្មោះ [redacted] បូរ៉ា បានមកទារអង្ករថ្លៃធ្វើស្រែពីខ្លួន តែពេលនោះនាងខ្លួនបាននិយាយថា ខ្លួនបានឲ្យអង្ករហើយ ហេតុអីមកទារទៀត។ ឃើញថា ចម្លើយនេះជាចម្លើយដោះសារតែប៉ុណ្ណោះ ពុំមានសាក្សីនិងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលគប្បីឲ្យជឿបានឡើយ ព្រោះថា ចម្លើយនេះ មានភាពផ្ទុយគ្នាទៅនឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ។

៣-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បូរ៉ា បានបញ្ជាក់ថាៈ កាលពីដើមឆ្នាំ២០១៩ មានឈ្មោះ [redacted] សុខឃីម បានមកជួបខ្លួនដើម្បីទំនាក់ទំនងឆ្លុកជេរដីរបស់ខ្លួន ពេលនោះខ្លួនបានប្រាប់ថា មិនទាន់លក់ទេ ដីនេះគឺទុកធ្វើស្រែសម្រាប់យកស្រូវហូបទេ ពេលនោះជនជាប់ចោទបានស្នើសុំខ្លួនធ្វើស្រែប្រវាស់ដើម្បីយកស្រូវចែកគ្នា ដោយសន្យាថានឹងអោយផល៥០ភាគរយមកខ្លួន ។ ចំពោះការធ្វើស្រែក្នុងឆ្នាំ២០១៩ជនជាប់

ចោទបានធ្វើស្រែចំនួន២ដង ដោយលើកទី១ បានអោយខ្លួនបានប្រហែល៥០គីឡូក្រាម ហើយលើកទី២ បែរជាមិនចែកផលស្រូវមកអោយខ្លួនទាល់តែសោះ ថែមទាំងប្រមាថមើលងាយខ្លួនទៀតផង ។

៤-ទាំងចម្លើយជនត្រូវចោទ ទាំងចម្លើយដើមបណ្តឹង និងរបាយការណ៍របស់មន្រ្តីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងឯកសារនានា មានភាពស៊ីសង្វាក់គ្នាដែលកំណត់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែន ។

៥-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ប្រាកដមែន ។

៦-អំពើរបស់ជនជាប់ចោទបានស្តែងឡើងដោយ មានចេតនា គៃបំបាត់នូវផលស្រូវ ដែលបានសន្យាថានឹងចែកផលស្រូវទៅឲ្យជនរងគ្រោះ តែពេលបានផលហើយបែរជាមិនបានចែកផលនោះទៅឲ្យជនរងគ្រោះដោយធ្វើឲ្យជនរងគ្រោះបាត់បង់នូវផលប្រយោជន៍ ដែលអំពើនេះច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ និងមានចែងក្នុងមាត្រា **៣៩១** និងមាត្រា **៣៩២** នៃក្រមព្រហ្មទណ្ឌ ។

៧-ជនជាប់ចោទ ជានីតិជន បានប្រព្រឹត្តបទល្មើសដោយមានចេតនា និងការយល់ដឹងពីអំពើរបស់ខ្លួន ដូច្នេះជនទាំងនេះត្រូវទទួលខុសត្រូវនូវទង្វើដែលខ្លួនបានប្រព្រឹត្តចំពោះច្បាប់ ។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សុខឃីម** ដែលមានសាវតាដូចខាងលើ ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិស្វាយ ឃុំព្រៃព្រួច ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

៩-គប្បីតុលាការប្រកាសទណ្ឌកម្មលើជនជាប់ចោទក្នុងកំរិតដាក់ពន្ធនាគារ ១(មួយ)ឆ្នាំ និងឲ្យអនុវត្តទោសព្យួរធម្មតា ដោយពិចារណាទៅលើភាពធ្ងន់ស្រាលនៃបទល្មើស និងសកម្មភាពល្មើសរបស់ជនជាប់ចោទ ដូចខាងក្រោម:

+អំពើល្មើសរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់ ទ្រព្យសម្បត្តិរបស់អ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម។

+សកម្មភាពល្មើសពុំបង្កឲ្យមានព្យសនៈកម្មធ្ងន់ធ្ងរឡើយ។ មូលហេតុទាំងនេះនាំឲ្យតុលាការ ពិចារណាប្រកាសទោសក្នុងកំរិតខាងលើដល់ជនជាប់ចោទ ។

១០-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមក ឃើញថា ពិតជាមាននូវអង្គហេតុនៃអំពើ រំលោភលើទំនុកចិត្ត ប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោឈ្មោះ [redacted] សុខឃីម ។ ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទពីបទ រំលោភលើទំនុកចិត្ត ។ រក្សាបទចោទប្រកាន់តាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះលេខផ្ទាល់លេខៈ **៤៩៧** ដក.ជរជ/២០ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ស្នើសុំឲ្យតុលាការសម្រេចតាមច្បាប់ ។ តុលាការយល់ស្របនឹងសេចក្តីសន្និដ្ឋាននេះ ។

១១-សំណូមពរចុងក្រោយរបស់ជនជាប់ចោទ៖ ស្នើសុំឲ្យតុលាការលើកលែងការចោទប្រកាន់។ គប្បីតុលាការពិចារណា។

## សម្រេច

១.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **សុខឃីម** ភេទស្រី អាយុ៥៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតនៅភូ[redacted]ខេត្តកណ្តាល និងទីលំនៅ

បច្ចុប្បន្ននៅភូមិអូរកំបុត ឃុំ  ព្រៃព្រួច ស្រុកអង្គស្នួល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] អ៊ុយ (ស្លាប់) ម្តាយឈ្មោះ [redacted] ស៊ួយ (ស្លាប់) ប្តីឈ្មោះ [redacted] ហួល ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាក់ពន្ធនាគាកំណត់រយៈពេល ១(មួយ)ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា ពីបទ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិ ស្វាយ ឃុំព្រៃព្រួច ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៩១** និងមាត្រា **៣៩២** នៃក្រមព្រហ្មទណ្ឌ ។

២.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] **សុខឃីម** ដែលមានសាវតាជាតិដូចខាងលើ សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១.០០០.០០០រ (មួយលានរៀល) ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៉ូរ៉ា សំណើរលើសពីនេះបដិសេធចោល ។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា៖ [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា៖ [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៦រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅកណ្តាល, ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]